## តើអ្នកណាត្រូវធ្វើតេស្ត MCAS?

សិស្សទាំងអស់នៅថ្នាក់ទី 3 ដល់ទី 8 និងទី 10 ដែលចូលរៀននៅសាលាដែលទទួលបានការឧបត្ថម្ភថវិកាពីរដ្ឋ តម្រូវឱ្យចូលរួមក្នុងការវាយតម្លៃ MCAS ទូទាំងរដ្ឋ។ សិស្សមួយចំនួនតូចដែលមានពិការភាពខ្លាំងបំផុតប្រឡងលើការវាយតម្លៃជំនួសតាមប្រព័ន្ធវាយតម្លៃដ៏ទូលំទូលាយរបស់រដ្ឋ Massachusetts (MCAS-Alt) ប្រសិនបើពួកគេមិនអាចធ្វើតេស្តតាមប្រព័ន្ធវាយតម្លៃដ៏ទូលំទូលាយទូទៅរបស់រដ្ឋ Massachusetts (MCAS) ទេ ទោះមានការសម្របសម្រួលក៏ដោយ។

សិទ្ធិចូលរួមក្នុងការវាយតម្លៃជំនួសត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំដោយផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់ក្រសួងអប់រំបឋមសិក្សា និងមធ្យមសិក្សានៃរដ្ឋ Massachusetts (DESE) ដោយក្រុមការងារនៃកម្មវិធីអប់រំជាលក្ខណៈបុគ្គល (IEP) របស់សិស្ស ដែលរួមបញ្ចូលទាំងឪពុកម្តាយ/អាណាព្យាបាល។ សិស្សដែលប្រឡងលើការវាយតម្លៃជាជំនួសទទួលការណែនាំជាលក្ខណៈបុគ្គល ដែលបានកែប្រែយ៉ាងច្រើនពីការបង្រៀនដែលសិស្សដទៃទៀតទទួលបាន។ សូមជ្រាបជូនថា ការចូលរួមក្នុងការវាយតម្លៃ MCAS-Alt ប្រហែលជាអាចប៉ះពាល់ដល់សមត្ថភាពរបស់កូនអ្នកក្នុងការទទួលបានសញ្ញាបត្រវិទ្យាល័យ។

## ហេតុអ្វីបានជាដាក់បញ្ចូលសិស្សពិការទៅក្នុងតេស្ត MCAS និង MCAS-Alt?

**វាជាច្បាប់។**
ច្បាប់រដ្ឋ និងសហព័ន្ធតម្រូវឱ្យមានការចូលរួមពីសិស្សទាំងអស់នៅក្នុងការវាយតម្លៃទូទាំងរដ្ឋ។ ការវាយតម្លៃជាជម្រើសនេះអនុញ្ញាតឱ្យសិស្សដែលមានពិការភាពខាងប្រាជ្ញាធ្ងន់ធ្ងរបំផុតដែលមិនអាចធ្វើតេស្ត MCAS ទូទៅអាច "បង្ហាញចំណេះដឹងរបស់ខ្លួន" និងទទួលបានការបង្រៀននៅកម្រិតមួយដែលអាចល្បងសមត្ថភាព និងអាចសម្រេចបានសម្រាប់ពួកគេ។

**MCAS ជួយកំណត់ថា តើសិស្សកំពុងរៀនចេះបានកម្រិតណាដែរ។**
ការវាយតម្លៃ MCAS-Alt បង្ហាញអំពីជំនាញអ្វីខ្លះដែលសិស្សបានរៀនចេះក្នុងអំឡុងពេលឆ្នាំសិក្សា។ ពិន្ទុដែលសម្រេចបានផ្តល់មតិកែលម្អដែលអាចប្រើប្រាស់ក្នុងការកំណត់គោលដៅដែលប្រឈម និងការបង្រៀនសម្រាប់ពេលអនាគត។

**ការរាប់បញ្ចូលសិស្សទាំងអស់ធានាឱ្យបានថា សិស្សគ្រប់រូបទទួលបានការបង្រៀន។**
ការរាប់លទ្ធផលរបស់សិស្សដែលធ្វើតេស្ត MCAS-Alt មានន័យថាសិស្សទាំងនោះទំនងជាត្រូវបានគេពិចារណានៅពេលមានការសម្រេចចិត្តលើធនធាន។

**នៅពេលដែលការរៀនសូត្រមានភាពប្រសើរឡើង ការរំពឹងទុកក៏កើនឡើងដែរ។**
ភស្តុតាងបង្ហាញថា សិស្សរៀនបានកាន់តែច្រើននៅពេលពួកគេចូលរួមក្នុងការបង្រៀនផ្អែកលើស្តង់ដារសិក្សារបស់រដ្ឋ ហើយនៅពេលពួកគេចូលរួមក្នុងការវាយតម្លៃផ្អែកលើស្តង់ដារសិក្សាទាំងនោះ។

## តើលទ្ធផលតេស្ត MCAS-Alt ត្រូវបានប្រើប្រាស់ដោយរបៀបណា?

លទ្ធផលតេស្ត MCAS-Alt គួរតែត្រូវបានប្រើដោយសាលា និងក្រុម IEP ដើម្បី៖

- កំណត់គោលដៅសិក្សាដែលប្រឈម និងរៀបចំផែនការបង្រៀនសម្រាប់សិស្ស
- វាស់ស្ទង់ការរីកចម្រើនរបស់សិស្សក្នុងការទទួលបាននូវជំនាញដោយផ្អែកលើស្តង់ដាសិក្សាជំនួសពីក្របខណ្ឌកម្មវិធីសិក្សារបស់រដ្ឋ Massachusetts
- បែងចែកធនធានសាលាគ្រប់គ្រាន់សម្រាប់ការអប់រំរបស់សិស្ស
- បង្កើតថាតើសាលា និងមណ្ឌលសិក្សាកំពុងមានការរីកចម្រើនក្នុងការអប់រំសិស្សដែលមានពិការភាពខ្លាំងបំផុតដែរឬអត់

## តើសិស្សអាចបំពេញតាមលក្ខខណ្ឌនៃការបញ្ចប់ការសិក្សារបស់រដ្ឋ និងទទួលបានសញ្ញាប័ត្របើពួកគេចូលរួមក្នុងតេស្ត MCAS-Alt ដែរឬទេ?

យើងចង់ឱ្យអ្នកដឹងថា ការចូលរួមក្នុងការវាយតម្លៃជាជម្រើសផ្សេងអាចប៉ះពាល់ដល់សមត្ថភាពរបស់កូនអ្នកក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវរបស់រដ្ឋ ដើម្បីទទួលបានសញ្ញាបត្រវិទ្យាល័យ ព្រោះ MCAS-Alt វាយតម្លៃទៅលើស្តង់ដានៃការសិក្សាដែលមានកម្រិត**ទាប**ជាងការរំពឹងទុក ដែលចាំបាច់ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវចំពោះការបញ្ចប់ការសិក្សារបស់រដ្ឋ។ ដូច្នេះហើយ សិស្សដែលបានចូលរួមក្នុងតេស្ត MCAS-Alt នឹងមិនអាចបំពេញបានតាមលក្ខខណ្ឌនៃការបញ្ចប់ការសិក្សារបស់រដ្ឋនោះទេ។

គោលបំណងរបស់លក្ខខណ្ឌបញ្ចប់ការសិក្សារបស់រដ្ឋគឺដើម្បីធានាថា សិស្សដែលទទួលបានសញ្ញាបត្រនៅក្នុងរដ្ឋ Massachusetts អាចបង្ហាញនូវសមត្ថភាពជាគោលនៅក្នុងមុខវិជ្ជាអក្សរសាស្ត្រអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម មុនពេលចូលទៅក្នុងថ្នាក់អប់រំក្រោយមធ្យមសិក្សា ឬក្នុងកន្លែងការងារ។ លក្ខខណ្ឌតម្រូវនេះត្រូវបានដាក់ឱ្យមានសម្រាប់សិស្សទាំងអស់ដោយចាប់ផ្តើមជាមួយនឹងថ្នាក់បញ្ចប់ការសិក្សាក្នុងឆ្នាំ 2003 ។ អ្នកអាចស្វែងយល់បន្ថែមទៀតអំពីលក្ខខណ្ឌតម្រូវចំពោះការបញ្ចប់ការសិក្សានៅគេហទំព័រ www.doe.mass.edu/mcas/graduation.html។

ដើម្បីបំពេញតាមលក្ខខណ្ឌបញ្ចប់ការសិក្សារបស់រដ្ឋ សិស្សត្រូវតែធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងក្រោម៖

- ត្រូវធ្វើតេស្ត និងប្រឡងឱ្យជាប់តេស្ត MCAS។
- បញ្ជូននូវឯកសារបង្ហាញសមត្ថភាព ដែលបង្ហាញអំពីចំណេះដឹង និងជំនាញរបស់សិស្សនៅកម្រិតសមិទ្ធផលថ្នាក់ទី 10 ឬ
- ទទួលបានឯកសារតវ៉ាលទ្ធផលក្នុងតេស្ត MCAS ដែលមានកត់ត្រាពិន្ទុជាមធ្យមតាមកម្រិតថ្នាក់របស់គេ ដោយប្រៀបធៀបជាមួយនឹងសិស្សដទៃដែលសិក្សានៅក្នុងមុខវិជ្ជានៅកម្រិតថ្នាក់ដូចគ្នា។ ព័ត៌មានអំពីការតវ៉ាក្នុងតេស្ត MCAS មាននៅលើគេហទំព័រ https://www.doe.mass.edu/mcasappeals/។

## ចំពោះព័ត៌មានបន្ថែម

ប្រព័ន្ធវាយតម្លៃដ៏ទូលំទូលាយនៃរដ្ឋ Massachusetts (MCAS)..........www.doe.mass.edu/mcas
ការវាយតម្លៃជំនួសលើតេស្ត MCAS (MCAS-Alt)..........www.doe.mass.edu/mcas/alt
លក្ខខណ្ឌតម្រូវនៃការចូលរួមតេស្ត MCAS សម្រាប់សិស្សដែលមានពិការភាព..........www.doe.mass.edu/mcas/accessibility
លក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សា និងបណ្តឹងតវ៉ាលើលទ្ធផលតេស្ត MCAS..........www.doe.mass.edu/mcas/graduation.html
ប្រសិនបើអ្នកមានសំណួរ..........អ៊ីមែល៖ mcas@mass.gov



# របាយការណ៍សម្រាប់ឪពុកម្តាយ/អាណាព្យាបាលអំពីការវាយតម្លៃជំនួស (MCAS-Alt) ក្នុងតេស្ត MCAS និទាឃរដូវឆ្នាំ 2024

MASSACHUSETTS Department of Elementary and Secondary Education

**ឈ្មោះ៖** | **SASID៖**
**សាលា៖** | **ថ្នាក់៖**
**មណ្ឌល៖** | **ថ្ងៃខែឆ្នាំកំណើត៖**

ឯកសារដែលបានភ្ជាប់មកជាមួយគឺជាលទ្ធផលរបស់កូនអ្នកពីការវាយតម្លៃជំនួស MCAS ឆ្នាំ 2024 (MCAS-Alt)។ សិស្សទាំងអស់ត្រូវបានតម្រូវឱ្យចូលរួមធ្វើតេស្ត MCAS ដោយការធ្វើតេស្ត MCAS ស្តង់ដា ឬតាមរយៈការចូលរួមវាយតម្លៃជំនួស MCAS (MCAS-Alt) សម្រាប់សិស្សដែលមានពិការភាពខ្លាំងបំផុត ដែលបំពេញតាមលក្ខខណ្ឌតម្រូវនៃសិទ្ធិចូលរួម។ សាលារៀនរបស់កូនអ្នកបានដាក់ MCAS-Alt របស់ពួកគេកាលពីនិទាឃរដូវមុន ដូចដែលបានបញ្ជាក់នៅក្នុងផែនការ IEP ឬ 504 របស់ពួកគេ។ MCAS-Alt គឺជាកំណត់ត្រានៃកម្រិតសមិទ្ធផលរបស់កូនអ្នក រួមទាំងបណ្តុំកិច្ចការសិក្សារបស់គេ។ មុនពេលកំណត់ត្រានេះត្រូវបានដាក់បញ្ជូនមក សាលារបស់អ្នកត្រូវអញ្ជើញអ្នកឱ្យពិនិត្យមើលការវាយតម្លៃរបស់កូនអ្នក។

សូមជួបគ្រូបង្រៀនរបស់កូនអ្នកដើម្បីពិភាក្សាពីអត្ថន័យនៃលទ្ធផលទាំងនេះ និងជជែកអំពីគោលដៅរបស់កូនអ្នកសម្រាប់ឆ្នាំសិក្សាខាងមុខ។ ការគាំទ្ររបស់អ្នកគឺមានសារសំខាន់ខ្លាំងណាស់។ ក្រសួងអប់រំបឋមសិក្សា និងមធ្យមសិក្សាសូមទទួលស្គាល់នូវការខិតខំប្រឹងប្រែងរបស់គ្រូបង្រៀនចំពោះកូនអ្នកក្នុងការចងក្រង MCAS-Alt នេះ និងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ និងមានប្រយោជន៍។

## លទ្ធផលសរុបរបស់កូនអ្នក

| អក្សរសាស្ត្រអង់គ្លេស | គណិតវិទ្យា | វិទ្យាសាស្ត្រ និង បច្ចេកវិទ្យា/វិស្វកម្ម |
| --- | --- | --- |
| កម្រិតសមិទ្ធផល | កម្រិតសមិទ្ធផល | កម្រិតសមិទ្ធផល |

## គោលបំណងនៃតេស្ត MCAS-Alt

MCAS-Alt គឺជាការវាយតម្លៃដែលបង្កើតឡើងដើម្បីវាស់ស្ទង់សមិទ្ធផលរបស់សិស្សដែលមានពិការភាពខាងប្រាជ្ញាខ្លាំងបំផុតទៅលើមុខវិជ្ជាមួយចំនួនដូចជាអក្សរសាស្ត្រអង់គ្លេស គណិតវិទ្យា និងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម។ កូនរបស់អ្នកត្រូវបានរំពឹងថានឹងបង្ហាញពីចំណេះដឹងកម្រិតបទដ្ឋានសិក្សារបស់រដ្ឋនៅកម្រិតមួយដែលមានការប្រកួតប្រជែង និងសមស្រប។

គោលបំណងនៃតេស្ត MCAS-Alt គឺដើម្បីធានាថា សាលាកំពុងបង្រៀនតាមស្តង់ដារដល់សិស្សទាំងអស់ ដោយមិនគិតពីភាពពិការរបស់ពួកគេ និងសូម្បីតែនៅពេលពួកគេមិនអាចបង្ហាញពីចំណេះដឹងរបស់ពួកគេនៅលើតេស្តស្តង់ដារក៏ដោយ។

## តើ MCAS-Alt គឺជាអ្វី?

MCAS-Alt របស់កូនអ្នករួមបញ្ចូលទាំងគំរូកិច្ចការសាលារបស់គេនិងកំណត់ត្រាអំពីការរីកចម្រើនរបស់គេនៅក្នុងមុខវិជ្ជាដែលកំពុងធ្វើការវាយតម្លៃ។ ការវាយតម្លៃនីមួយៗរួមបញ្ចូលទាំងគំរូកិច្ចការ និងឯកសារអំពីការរីកចម្រើននៅក្នុងមុខវិជ្ជាដូចគ្នា ដែលបានវាយតម្លៃនៅក្នុងតេស្ត MCAS ស្តង់ដាសម្រាប់សិស្សនៅក្នុងថ្នាក់នោះ។ សិស្សដែលប្រឡង MCAS-Alt កំពុងធ្វើការលើចំណេះដឹង និងជំនាញដោយផ្អែកលើស្តង់ដាសមិទ្ធិផលជំនួស។ ធាតុបន្ថែមអំពី MCAS-Alt ត្រូវបានផ្តល់ជូននៅក្នុង សៀវភៅណែនាំអ្នកអប់រំ (Educatorís Manual) សម្រាប់ MCAS-Alt ដែលអាចរកបាននៅគេហទំព័រ http://www.doe.mass.edu/mcas/alt/edmanual.docx។

ឈ្មោះ៖
SASID៖

ថ្នាក់៖
និទាឃរដូវ ឆ្នាំ 2024

## កត្តាពិពណ៌នាកម្រិតនិទ្ទេស

| | |
|---|---|
| **លើសពីការរំពឹងទុក** | សិស្សដែលមានលទ្ធផលនៅកម្រិតនេះ **លើសពីការរំពឹងទុកក្នុងកម្រិតនិទ្ទេស**ដោយបង្ហាញភាពស្ទាត់ជំនាញក្នុងមុខវិជ្ជា។ |
| **បំពេញតាមការរំពឹងទុក** | សិស្សដែលមានលទ្ធផលនៅកម្រិតនេះ **បានបំពេញតាមការរំពឹងទុកក្នុងកម្រិតនិទ្ទេស**និងសិក្សាទាន់តាមកម្មវិធីដើម្បីទទួលបានជោគជ័យនៅក្នុងនិទ្ទេសបច្ចុប្បន្នក្នុងមុខវិជ្ជានេះ។ |
| **បំពេញតាមការរំពឹងទុកដោយផ្នែក** | សិស្សដែលមានលទ្ធផលនៅកម្រិតនេះ **បំពេញតាមការរំពឹងទុកក្នុងកម្រិតនិទ្ទេសដោយផ្នែកខ្លះ**ក្នុងមុខវិជ្ជានេះ។ ដោយពិគ្រោះយោបល់ជាមួយមាតាបិតា/អាណាព្យាបាលរបស់សិស្ស សាលារៀនគួរតែពិចារណាថាតើសិស្សត្រូវការជំនួយផ្នែកសិក្សាបន្ថែមដើម្បីជោគជ័យក្នុងមុខវិជ្ជានេះដែរឬទេ។ |
| **មិនបានបំពេញតាមការរំពឹងទុក** | សិស្សដែលមានលទ្ធផលនៅកម្រិតនេះ **មិនបានបំពេញតាមការរំពឹងទុកក្នុងកម្រិតនិទ្ទេស**ទីនៅក្នុងមុខវិជ្ជានេះទេ។ សាលា ដោយមានការពិគ្រោះយោបល់ជាមួយឪពុកម្តាយរបស់សិស្ស/អាណាព្យាបាល គួរតែកំណត់ជំនួយសម្របសម្រួលផ្នែកអប់រំនិង/ឬការបង្ហាត់បង្រៀនបន្ថែមដែលសិស្សត្រូវការដើម្បីជោគជ័យក្នុងមុខវិជ្ជានេះ។ |
| **កំពុងរីកចម្រើន** | សិស្សនៅកម្រិតនេះបានបង្ហាញ **អំពីការយល់ដឹងដោយផ្នែកខ្លះក្រោមការរំពឹងទុកនៃកម្រិតនិទ្ទេស** ចំពោះស្តង់ដាដែលបានជ្រើសរើស និងប្រធានបទអំពីចំណេះដឹងមូលដ្ឋានដែលមាននៅក្នុងក្របខណ្ឌកម្មវិធីសិក្សានៃរដ្ឋ Massachusetts សម្រាប់មុខវិជ្ជានេះ។ សិស្សនៅកម្រិតនេះកំពុងរៀនសូត្រចំណេះដឹង ជំនាញ និងគោលគំនិតថ្មីៗ។ សិស្សទាមទារការណែនាំ និងជំនួយតិចតួច ហើយការអនុវត្តរបស់ពួកគេមានភាពត្រឹមត្រូវជាមូលដ្ឋាន។ |
| **កំពុងអភិវឌ្ឍ** | សិស្សនៅកម្រិតនេះបានបង្ហាញ **អំពីការយល់ដឹងធម្មតាក្រោមការរំពឹងទុកនៃកម្រិតនិទ្ទេស** ចំពោះស្តង់ដាមួយចំនួនដែលមានកំណត់ និងប្រធានបទអំពីចំណេះដឹងមូលដ្ឋានដែលមាននៅក្នុងក្របខណ្ឌកម្មវិធីសិក្សានៃរដ្ឋ Massachusetts សម្រាប់មុខវិជ្ជានេះ។ សិស្សនៅកម្រិតនេះទាមទារការណែនាំ និងជំនួយញឹកញាប់ ហើយការអនុវត្តរបស់ពួកគេមានកម្រិត និងមិនជាប់លាប់។ |
| **ការយល់ដឹង** | សិស្សនៅកម្រិតនេះបានបង្ហាញ **អំពីការយល់ដឹងតិចតួច** អំពីស្តង់ដា និងប្រធានបទអំពីចំណេះដឹងមូលដ្ឋានដែលមាននៅក្នុងក្របខណ្ឌកម្មវិធីសិក្សានៃរដ្ឋ Massachusetts សម្រាប់មុខវិជ្ជានេះ។ សិស្សនៅកម្រិតនេះទាមទារការណែនាំ និងជំនួយយ៉ាងច្រើន ហើយការអនុវត្តរបស់ពួកគេភាគច្រើនមិនត្រឹមត្រូវ។ |
| **មិនពេញលេញ** | **ភស្តុតាង និងព័ត៌មានគ្រប់គ្រាន់** មិនត្រូវបានបញ្ចូលមកក្នុងការវាយតម្លៃនេះដើម្បីអនុញ្ញាតឱ្យកំណត់កម្រិតសមិទ្ធផលនៅក្នុងមុខវិជ្ជានេះទេ។ |

ផ្នែកខាងលើនេះបង្ហាញពីកម្រិតនិទ្ទេសរួមរបស់កូនអ្នកក្នុងមុខវិជ្ជានីមួយៗនៃការវាយតម្លៃជាជម្រើស។
មុខវិជ្ជាក្នុងតេស្ត MCAS Alt ត្រូវបានផ្តល់ពិន្ទុតាមផ្នែកនីមួយៗដូចដែលបង្ហាញខាងក្រោម។ ពិន្ទុសម្រាប់ កម្រិតនៃភាពស្មុគស្មាញ ការបង្ហាញពីជំនាញ និងគោលគំនិត (ភាពត្រឹមត្រូវ) និងកម្រិតនៃភាពស្មុគស្មាញ ការបង្ហាញពីជំនាញ និងគោលគំនិត ត្រូវបានបញ្ចូលគ្នាដើម្បីផ្តល់កម្រិតនិទ្ទេសរួម។

## កម្រិតសមិទ្ធផលរបស់កូនអ្នក៖(✓)

| អក្សរសាស្ត្រអង់គ្លេស | គណិតវិទ្យា | វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម |
|---|---|---|

**គន្លឹះទៅកាន់អត្ថបទដែលអ្នកអាចមើលលើរបាយការណ៍របស់កូនអ្នក៖**

**NOT** ASSESSED FOR A STUDENT IN THIS GRADE
[**មិន**បានវាយតម្លៃសម្រាប់សិស្សនៅក្នុងនិទ្ទេសនេះទេ]

REQUIRED BUT **NOT SUBMITTED**
[បានតម្រូវតែ**មិនបានដាក់បញ្ជូនទេ**]

STUDENT TOOK STANDARD TEST
[សិស្សបានធ្វើតេស្តស្តង់ដា]

ABSENT
[អវត្តមាន]

## ចំណុចដាក់ពិន្ទុសម្រាប់តេស្ត MCAS-Alt និងពិន្ទុរបស់កូនអ្នក

### អក្សរសាស្ត្រអង់គ្លេស

| | កម្រិតនៃភាពស្មុគស្មាញ | ការបង្ហាញពីជំនាញ និងគោលគំនិត | ភាពឯករាជ្យម្ចាស់ការ | ស្វ័យវាយតម្លៃ | លទ្ធផលទូទៅ |
|---|---|---|---|---|---|
| | 1 2 3 4 5 | M 1 2 3 4 | M 1 2 3 4 | M 1 2 | 1 2 |
| ភាសា | ☐☐☐☐☐ | ☐☐☐☐☐ | ☐☐☐☐☐ | ☐☐☐ | ☐☐ |
| ការអាន | ☐☐☐☐☐ | ☐☐☐☐☐ | ☐☐☐☐☐ | ☐☐☐ | ☐☐ |
| សំណេរ | ☐☐☐☐☐ | ☐☐☐☐☐ | ☐☐☐☐☐ | ☐☐☐ | ☐☐ |

### គណិតវិទ្យា

| | កម្រិតនៃភាពស្មុគស្មាញ | ការបង្ហាញពីជំនាញ និងគោលគំនិត | ភាពឯករាជ្យម្ចាស់ការ | ស្វ័យវាយតម្លៃ | លទ្ធផលទូទៅ |
|---|---|---|---|---|---|

**គន្លឹះក្នុងការសរសេរអត្ថបទ អ្នកអាចមើលនៅក្នុងប្រអប់ខាងលើ នៅលើរបាយការណ៍របស់កូនអ្នក៖**

Expressions and Equations
[កន្សោម និងសមីការ]

Functions
[អនុគមន៍]

Measurement and Data
[រង្វាស់រង្វាល់ និងទិន្នន័យ]

Operations and Algebraic Thinking
[ប្រមាណវិធី និងការគិតបែបពិជគណិត]

Number and Operations in Base Ten
[ចំនួន និងប្រមាណវិធីក្នុងគោលដប់]

Number and Operations – Fractions
[ចំនួន និងប្រមាណវិធី - ប្រភាគ]

Geometry
[ធរណីមាត្រ]

Algebra
[ពិជគណិត]

Ratios and Proportional Relationships
[អនុបាត និងទំនាក់ទំនងសមាមាត្រ]

Statistics and Probability
[ស្ថិតិ និងប្រូបាប៊ីលីតេ]

The Number System
[ប្រព័ន្ធលេខ]

Number and Quantity
[ចំនួន និងបរិមាណ]

### វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា/វិស្វកម្ម

| | កម្រិតនៃភាពស្មុគស្មាញ | ការបង្ហាញពីជំនាញ និងគោលគំនិត | ភាពឯករាជ្យម្ចាស់ការ | ស្វ័យវាយតម្លៃ | លទ្ធផលទូទៅ |
|---|---|---|---|---|---|

**គន្លឹះក្នុងការសរសេរអត្ថបទដែលអ្នកអាចមើលនៅក្នុងប្រអប់ខាងលើនៅលើរបាយការណ៍របស់នអ្នក៖**

Earth and Space Science
[ផែនដី និងវិទ្យាសាស្ត្រលំហ]

Life Science
[វិទ្យាសាស្ត្រជីវិត]

Biology
[ជីវវិទ្យា]

Chemistry
[គីមីវិទ្យា]

Physical Sciences
[វិទ្យាសាស្ត្ររូបវន្ត]

### ឯកសាររបស់កូនអ្នកត្រូវបានដាក់ពិន្ទុក្នុងផ្នែកដូចខាងក្រោម៖

**កម្រិតនៃភាពស្មុគស្មាញ — របៀបដែលកូនរបស់អ្នកបង្ហាញពីស្តង់ដាររៀនសូត្រក្នុងមុខវិជ្ជានីមួយៗ (មុខវិជ្ជា)**
5 - សិស្សបង្ហាញអំពីស្តង់ដានៃការរៀនសូត្រតាមកម្មវិធីសិក្សាក្នុងកម្រិតជាច្រើន (បី ឬច្រើនជាងនេះ) ទៅតាមការរំពឹងទុកនៃកម្រិតនិទ្ទេសនៅក្នុងមុខជំនាញនេះ។
4 - សិស្សបង្ហាញអំពីគំរូស្តង់ដានៃការសិក្សាតាមក្របខណ្ឌកម្មវិធីសិក្សាមួយចំនួនតូច (មួយ ឬពីរ) ទៅតាមការរំពឹងទុកនៃកម្រិតនិទ្ទេសនៅក្នុងមុខជំនាញនេះ។
3 - សិស្សបង្ហាញអំពីស្តង់ដានៃការរៀនសូត្រតាមកម្មវិធីសិក្សាដែលត្រូវបានកែប្រែក្រោមការរំពឹងទុកនៃកម្រិតនិទ្ទេសនៅក្នុងមុខជំនាញនេះ។
2 - សិស្សបង្ហាញជាចម្បងលើជំនាញទំនាក់ទំនងក្នុងសង្គម ជំនាញចលនា និង ៲ ជំនាញប្រាស្រ័យទាក់ទង៎ ក្នុងអំឡុងពេលបង្រៀនដោយផ្អែកលើស្តង់ដានៃការរៀនសូត្រតាមក្របខណ្ឌកម្មវិធីសិក្សាក្នុងមុខជំនាញនេះ។
1- មុខជំនាញនេះឆ្លុះបញ្ចាំងអំពីមូលដ្ឋានគ្រឹះតិចតួច ឬគ្មានមូលដ្ឋានគ្រឹះ ឬមិនត្រូវគ្នានឹងស្តង់ដានៃការរៀនសូត្រតាមក្របខណ្ឌកម្មវិធីសិក្សាសម្រាប់ការវាយតម្លៃ។

**ការបង្ហាញជំនាញ និងគោលគំនិត — ភាគរយនៃការឆ្លើយតបត្រឹមត្រូវ (ជាក់ស្តែង)**
4 - លទ្ធផលរបស់សិស្សមានភាពត្រឹមត្រូវ និងមានគុណភាពខ្ពស់ដោយស្របគ្នានៅក្នុងមុខជំនាញនេះ (ត្រឹមត្រូវពី76–100%)។
3 - លទ្ធផលរបស់សិស្សមានភាពត្រឹមត្រូវដ៏ច្រើន និងបង្ហាញអំពីការយល់ដឹងមួយចំនួននៅក្នុងមុខជំនាញនេះ (ត្រឹមត្រូវ ពី 51–75%)។
2 - លទ្ធផលរបស់សិស្សមានកម្រិត និងមិនស្របគ្នាដែលទាក់ទងទៅនឹងភាពត្រឹមត្រូវ និងបង្ហាញអំពីការយល់ដឹងមានកម្រិតនៅក្នុងមុខជំនាញនេះ (ត្រឹមត្រូវពី 26–50%)។
1 - លទ្ធផលរបស់សិស្សគឺមានភាពមិនត្រឹមត្រូវជាចម្បង និងបង្ហាញអំពីការយល់ដឹងតិចតួចបំផុតនៅក្នុងមុខជំនាញនេះ (ត្រឹមត្រូវពី 0–25%)។
M -មុខជំនាញនេះមានព័ត៌មានមិនគ្រប់គ្រាន់ដើម្បីកំណត់ពិន្ទុនោះទេ។

**ភាពឯករាជ្យម្ចាស់ការ — ចំនួននៃជំនួយដែលកូនរបស់អ្នកបានទទួល**
4 - សិស្សតម្រូវឱ្យមានជំនួយតិចតួចបំផុតលើផ្នែករាងកាយ ចក្ខុ និងពាក្យសម្ដីដើម្បីបង្ហាញអំពីជំនាញ និងគំនិតនៅក្នុងមុខជំនាញនេះ (ឯករាជ្យ 76–100%)។
3 - សិស្សតម្រូវឱ្យមានជំនួយមួយចំនួនលើផ្នែករាងកាយ ចក្ខុ និងពាក្យសម្ដីដើម្បីបង្ហាញអំពីជំនាញ និងគំនិតនៅក្នុងមុខជំនាញនេះ (ឯករាជ្យពី 51–75%)។
2 - សិស្សតម្រូវឱ្យមានជំនួយញឹកញាប់លើផ្នែករាងកាយ ចក្ខុ និងពាក្យសម្ដីដើម្បីបង្ហាញអំពីជំនាញ និងគំនិតនៅក្នុងមុខជំនាញនេះ (ឯករាជ្យពី 26–50%)។
1 - សិស្សតម្រូវឱ្យមានជំនួយទូលំទូលាយលើផ្នែករាងកាយ ចក្ខុ និងពាក្យសម្ដីដើម្បីបង្ហាញអំពីជំនាញ និងគំនិតនៅក្នុងមុខជំនាញនេះ (ឯករាជ្យពី 0–25%)។
M -មុខជំនាញនេះមានព័ត៌មានមិនគ្រប់គ្រាន់ដើម្បីកំណត់ពិន្ទុនោះទេ។

**ការវាយតម្លៃខ្លួនឯង — ការយល់ដឹងរបស់កូនអ្នកអំពីលទ្ធផលរបស់ពួកគេ។**
2 - ជាញឹកញាប់ សិស្សរៀបចំផែនការ កែតម្រូវដោយខ្លួនឯង តាមដាន កំណត់គោលដៅ និងឆ្លុះបញ្ចាំងនៅក្នុងមុខវិជ្ជានេះ ឧទាហរណ៍ជាច្រើនអំពីស្វ័យវាយតម្លៃត្រូវបានរកឃើញនៅក្នុងមុខជំនាញនេះ។
1 - សិស្សមិនសូវរៀបចំផែនការ កែតម្រូវដោយខ្លួនឯង តាមដាន កំណត់គោលដៅ និងឆ្លុះបញ្ចាំងនៅក្នុងមុខវិជ្ជានេះទេ មានតែឧទាហរណ៍មួយគត់អំពីស្វ័យវាយតម្លៃ ដែលបានរកឃើញនៅក្នុងមុខជំនាញនេះ។
M -ភស្តុតាងនៃការរៀបចំផែនការ ការកែតម្រូវដោយខ្លួនឯង ការតាមដានកិច្ចការ ការកំណត់គោលដៅ និងការឆ្លុះបញ្ចាំងមិនត្រូវបានរកឃើញនៅក្នុងឯកសាររបស់សិស្សនៅក្នុងមុខជំនាញនេះទេ។

**លទ្ធផលទូទៅ — ចំនួននៃវិធីសាស្ត្រដែលបានប្រើដោយកូនរបស់អ្នកដើម្បីបង្ហាញចំណេះដឹង និងជំនាញ**
2 - សិស្សបង្ហាញចំណេះដឹង និងជំនាញនៅក្នុងបរិបទជាច្រើន ឬប្រើវិធីសាស្ត្រជាច្រើន និង/ឬវិធីសាស្ត្រនៃការឆ្លើយតប និងការចូលរួមនៅក្នុងមុខជំនាញនេះ។
1 - សិស្សបង្ហាញចំណេះដឹង និងជំនាញក្នុងបរិបទមួយ ឬប្រើវិធីសាស្ត្រមួយ និង/ឬវិធីសាស្ត្រនៃការឆ្លើយតប និងការចូលរួមនៅក្នុងមុខជំនាញនេះ។